**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ**.......................

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា នឹងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ **កិច្ចប្រជុំលើកទី១៤** ***នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ*** (The 14th General Border Committee Meeting "GBC") នៅសណ្ឋាគារកាដែនស៊ីតធី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា **ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩** ក្រោមអធិបតីភាព **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា** សហប្រធានគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា និង**ឯកឧត្តម នាយឧត្តមសេនីយ៍ ប្រាវីត វង្សសុវណ្ណ** (Prawit wongsuwon) **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ** សហប្រធានគណៈកម្មាធិការព្រំដែនទូទៅថៃ។

ក្រោមកិច្ចព្រមព្រៀងឆ្នាំ២០០៦ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ***គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ*** (General Border Committee "GBC") មួយត្រូវបានបង្កើតឡើង ដោយមានការជួបប្រជុំប្តូរវេនយ៉ាងទៀងទាត់រៀងរាល់ឆ្នាំ ហើយក្នុងឆ្នាំ២០១៩នេះ កម្ពុជានឹងទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំលើកទី១៤ ដោយមានការអញ្ជើញចូលរួមពីគណៈប្រតិភូនៃគណៈកម្មាធិការព្រំដែនទូទៅ **កម្ពុជា-ថៃ** ដឹកនាំដោយ **សម្តេចពិជ័យសេនា ទៀ បាញ់** និងគណៈប្រតិភូនៃគណៈកម្មាធិការព្រំដែនទូទៅ ថៃ-កម្ពុជា ដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ប្រាវីត វង្សសុវណ្ណ** ។

កិច្ចប្រជុំលើកទី១៤នេះ ក៏ដូចជាកិច្ចប្រជុំមុនៗដែរ ភាគីទាំងពីរ នឹងបន្តកិច្ចពិភាក្សារបស់ខ្លួន ដោយផ្តោតយ៉ាងសំខាន់លើការពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ បង្កើតទំនាក់ទំនងល្អរវាងកងទ័ពនៃប្រទេសទាំងពីរ **កម្ពុជា-ថៃ** ក្នុងកិច្ចការពារ និងរក្សាឲ្យបានរឹងមាំនូវ សន្តិភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍តាមបណ្តោយព្រំដែន នៃប្រទេសទាំងពីរ និងរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាដែលអាចកើតមានឡើងនៅតាមបណ្តោយព្រំដែនរួមនៃប្រទេសជិតខាងទាំងពីរ ដើម្បីរក្សា និងធានាបាននូវ សេចក្តីសុខ ក្សេមក្សាន្ត និងជីវភាពរស់នៅរីកចំរើនរបស់ប្រជាជន នៃប្រទេសទាំងពីរ ៕

**ថ្ងៃច័ន្ទ ៧កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២**

**រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh